**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

## សារជូនពរ

**សូមគោរពជូន**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**
**ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៧៦ ឈានចូល ៧៧ ឆ្នាំ**

**សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់** !

ក្នុងឱកាសដ៏ឧត្តុង្គឧត្តម នៃពិធីចម្រើនជន្មាយុគម្រប់ ៧៦ ឈានចូល ៧៧ ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២១នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពល-ទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តីសិរីមង្គល មហាប្រសើរ ជូនចំពោះ **សម្តេចវិបុលសេនាភក្តី** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំស្ថាប័នព្រឹទ្ធសភាដែលជាស្ថាប័ននីតិប្បញ្ញត្តិកំពូល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យសម្រេចបាននូវជោគជ័យត្រចះត្រចង់ថ្មីៗថែមទៀត។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រចំពោះគុណវីរភាព និងកិច្ចខិតខំប្រឹងប្រែងយកអស់កម្លាំងកាយ និងប្រាជ្ញាស្មារតីរបស់ **សម្តេចវិបុលសេនាភក្តី** ក្នុងការដឹកនាំស្ថាប័ននីតិប្បញ្ញត្តិកំពូលរបស់ជាតិសម្រេចបាននូវស្នាដៃនិងសមិទ្ធផលធំៗជាច្រើន ឆ្លុះបញ្ចាំងឱ្យឃើញពីការខិតខំប្រឹងប្រែងពុំខ្លាចនឿយហត់របស់ **សម្តេច** ក៏ដូចជាស្ថាប័នព្រឹទ្ធសភាទាំងមូល ដែលបានដើរតួនាទីជាកម្លាំងចលករគាំទ្រដល់ការរក្សានូវនិរន្តរភាពក្នុងដំណើរអភិវឌ្ឍសង្គមជាតិ ឱ្យរីកចម្រើនថ្កុំថ្កើងរុងរឿង។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក តាមជួយបីបាច់ថែរក្សាប្រោះព្រំសព្ទសាធុការពរជ័យ ជូនចំពោះ **សម្តេចវិបុលសេនាភក្តី** និង**លោកជំទាវ** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ៩ កើត ខែ បុស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**